# ព័ត៌មាន ស្តីពីការចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំង ដល់អ្នកដែលបញ្ចប់ការចាក់ថ្នាំបង្ការនៅបរទេស(ក្រៅប្រទេសកូរ៉េ) ដើម្បីចាក់វ៉ាក់សាំងលើកទី៣

## □ ខ្លឹមសារ

O ជនបរទេស* ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅបរទេស ប៉ុន្តែមិនបានទទួលលិខិតលើកលែងការធ្វើចត្តាឡីស័កនៅពេលចូលមកក្នុងប្រទេសកូរ៉េនោះ ក៏អាចចាក់វ៉ាក់សាំងលើកទី៣ នៅប្រទេសកូរ៉េ បានដែរ

* (ជនបរទេស ដែលបានចាក់វ៉ាក់សាំងបង្ការ នៅបរទេស) ការចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងនៅបរទេស គឺសម្រាប់តែអ្នកកាន់លិខិតលើកលែងការធ្វើចត្តាឡីស័ក (៧.តុលា.២០២១~)

O អ្នកបានទទួលការចាក់វ៉ាក់សាំងបង្ការនៅអង្គភាពកងទ័ពសហរដ្ឋអាមេរិកនៅកូរ៉េ** ឬអ្នកជាច្រើនទៀតដែលមានការលំបាកក្នុងការចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងរបស់ពួកគេ ដោយសារការផ្លាក់ប្តូរអង្គភាព ដូចជាការចូលនិវត្តន៍ ឬលាលែងពីការងារផ្សេងៗ ក៏អាចចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងបានដែរ

**(កងទ័ពសហរដ្ឋអាមេរិកនៅកូរ៉េ អ្នកចាក់វ៉ាក់សាំងក្នុងប្រទេសកូរ៉េ) សម្រាប់ការចេញលិខិត(ប័ណ្ណ)ចាក់វ៉ាក់សាំងបង្ការ បន្ទាប់ពីចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងនៅអង្គភាពកងទ័ពសហរដ្ឋអាមេរិកនៅកូរ៉េ

## □ គោលបំណង

O ជនបរទេស ដែលបានចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងលើកទី១ និងទី២ តាមរយៈវិធានការនេះ គឺត្រូវបានចេញលិខិតបញ្ជាក់ពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅបរទេស(បូករួម COOV) ហើយអាចទទួលការចាក់វ៉ាក់សាំងលើកទី៣ និងអាចអនុវត្តប័ណ្ណឆ្លងកាត់ការបង្ការការរីករាលដាល

## □ គោលដៅវ៉ាក់សាំងដែលត្រូវចុះឈ្មោះ

O ការចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងបង្ការ គឺអនុវត្តចំពោះវ៉ាក់សាំងដែលបានអនុម័តដោយអង្គការសុខភាពពិភពលោកWHO តែប៉ុណ្ណោះ*

* ហ្វាយសឺរ, យ៉ាន់សេន, ម៉ូឌូណា, អាស្ត្រាហ្សឺនេកា, ខូវីស្សែល(AZ-វិទ្យាស្ថានស្រាវជ្រាវ សេរ៉ូមប្រទេសឥណ្ឌា), ស៊ីណូហ្វាម (ទីក្រុងប៉េកាំង), ស៊ីណូវ៉ាក់, ខូវ៉ាស៊ីន

O ជនបរទេសដែលមិនមានកាន់លិខិតលើកលែងការធ្វើចត្តាឡីស័ក គឺប្រសិនបើបានបញ្ចប់ចាក់វ៉ាក់សាំងលើកទី៣ ប្រវត្តិនៃការចាក់វ៉ាក់សាំងបង្ការ ត្រូវបានចុះនៅក្នុងប្រទេសកូរ៉េ

O ការលើកលែងធ្វើចត្តាឡីស័ក ក៏អាចអនុវត្តផងដែរ សម្រាប់ការចូលមកប្រទេសកូរ៉េម្តងទៀត និងពេលដែលបានប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺកូវីដ

## □ វិធីសាស្ត្រចុះឈ្មោះ

O ជនបរទេសដែលមានបំណងចង់ចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងបង្ការ នៅបរទេស គឺបន្ទាប់ពីអ្នកយកអត្តសញ្ញាណប័ណ្ណ និងវិញ្ញាបនបត្រនៃការចាក់ថ្នាំបង្ការនៅបរទេស ហើយសូមអ្នកទៅកាន់មណ្ឌលសុខភាពសាធារណៈដែលនៅជិត ដើម្បីចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងបង្ការ

<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូវី ១៥៧៧-១៣៦៦>